## រឿងទី៩៖ សាំសុន

**ខគម្ពីរ៖ ចៅហ្វាយ ១៦៖២០**

... លោកសាំសុនភ្ញាក់ពីដំណេក ហើយគិតថា លោកនឹងរំដោះខ្លួន ដូចសព្វមួយដង ព្រោះលោកពុំបានដឹងថា ព្រះ អម្ចាស់ថយចេញពីលោកនោះទេ។

ជនជាតិអ៊ីស្រាអែលបានប្រព្រឹត្តអំពើបាបយ៉ាងខ្លាំង ដូច្នេះព្រះបានបញ្ជូនពួកគេទៅក្នុងកណ្តាប់ដៃរបស់ពួកភីលីស្ទីន
មានថ្ងៃមួយ ទេវតារបស់ព្រះបានបង្ហាញខ្លួននៅក្នុងផ្ទះរបស់ម៉ាណូអាជាជនជាតិអ៊ីស្រាអែលដែលប្រពន្ធគាត់ ជាស្ត្រីអារគ្មានកូនសោះ។
«នាងនឹងមានផ្ទៃពោះបង្កើតបានកូនប្រុសម្នាក់។ ប៉ុន្តែ អ្នកមិនត្រូវកាត់សក់ក្បាលរបស់កូននោះឡើយ»។
ក្រោយមក ភរិយារបស់ម៉ាណូអាក៏បង្កើតបានកូនប្រុសម្នាក់។
ពួកគេបានដាក់ឈ្មោះឱ្យកូនថា សាំសុន។ ព្រះជាម្ចាស់បានគង់នៅជាមួយសាំសុន ហើយបានប្រទានពរដល់គេជាច្រើន។
សក់សាំសុនក៏លូតវែងណាស់ដែរ ប៉ុន្តែដោយនឹងចាំពីពាក្យរបស់ទេវតាទើបឪពុកម្តាយគាត់មិនកាត់សក់នោះទេ។
ពេលវេលាចេះតែកន្លងទៅ សាំសុនក៏បានធំពេញរូបពេញរាងក្លាយជាមនុស្សដែលមានកម្លាំងខ្លាំង។
ជនជាតិភីលីស្ទីនមានការខ្លាចរអារនិងសាំសុនដែលមានកម្លាំងខ្លាំងនោះណាស់។
សាំសុនមានកម្លាំងខ្លាំង រហូតដល់អាចប្រយុទ្ធយកឈ្នះសត្វតោដែលគាត់បានដើរជួបតាមផ្លូវយ៉ាងងាយ។
ប៉ុន្តែ ដោយសារជនជាតិអ៊ីស្រាអែលខ្លាចទទួលរងការធ្វើបាបពីជនជាតិភីលីស្ទិន ក៏ចាប់សាំសុនចង់នឹងខ្សែប្រគល់ ទៅឱ្យជនជាតិភីលីស្ទីន។
ប៉ុន្តែ ព្រះជាម្ចាស់បានប្រទានកម្លាំងដល់សាំសុន ឱ្យសាំលុនអាចផ្តាច់ខ្សែដែលចង់យ៉ាងជាប់នោះបានភ្លាម។
សាំសុនបានចាប់ចិត្តស្រឡាញ់ស្ត្រីសាសន៍ភីលីស្ទីនម្នាក់ឈ្មោះដេលីឡា
ដេលីឡាជាមនុស្សចូលចិត្តលុយខ្លាំង។
មានថ្ងៃមួយ ពេលសាំសុនកំពុងដេកលក់ ពួកស្តេចត្រាញ់របស់ជនជាតិភីលីស្ទីនបានទៅជួបដេលីឡា។
«ដេលីឡា ចូរនាងស៊ើបមើលថាតើសាំសុនមានកម្លាំងដ៏ខ្លាំងក្លានោះមកពីណា ហើយត្រូវធ្វើដូចម្តេចទើបអាចចាប់ ចង់សាំសុនបាន រួចមកប្រាប់ឱ្យយើងបានដឹង នោះយើងនឹងធ្វើឱ្យនាងក្លាយជាអ្នកមានស្តុកស្តម្ភ។
ចាប់ពីថ្ងៃនោះមក ដេលីឡា ក៏ចាប់ស៊ើបមើលថាតើសាំសុនទទួលបានកម្លាំងដ៏ខ្លាំងក្លានោះមកពីណា។
ប៉ុន្តែ សាំសុនមិនអាចប្រាប់ពីរឿងនោះដល់ស្ត្រីសាសន៍ភីលីស្ទីនបានទេ។
ប៉ុន្តែ ចុងក្រោយ ដោយព្រោះដេលីឡារំអុកខ្លាំងពេក សាំសុនក៏បានប្រាប់ពីអាថ៌កំបាំងរបស់ខ្លួន។



«ដេលីឡាអើយ ការពិតទៅ ខ្ញុំគឺជាមនុស្សរបស់ព្រះជាម្ចាស់តាំងពីកើតមកម្ល៉េះ ហើយកម្លាំងដ៏ខ្លាំងក្លាដែលខ្ញុំមាននេះ ក៏មកពីសក់របស់ខ្ញុំ។ បើខ្ញុំកាត់សក់នេះ នោះខ្ញុំនឹងគ្មានកម្លាំងទៀតទេ។»

ដេលីឡាដឹងរឿងនេះហើយ នាងក៏បានកាត់សក់សាំសុនពេលគាត់ដេកលក់។

ដូច្នេះ សាំសុនក៏បាត់បង់កម្លាំង។ ជនជាតិភីលីស្ទីន បានមកចាប់សាំសុនចង យកទៅដាក់គុក។

សាំសុន ព្យាយាមស្រាយចំណងនោះដែរ ប៉ុន្តែ គ្មានកម្លាំងធ្វើអ្វីកើតសោះ។

ដោយព្រោះព្រះជាម្ចាស់បានចាកចេញពីសាំសុន ទើបធ្វើឱ្យសាំសុនគ្មានកម្លាំងអ្វីទាល់តែសោះ។

ជនជាតិភីលីស្ទីនបានខ្វេះភ្នែកទាំងពីររបស់សាំសុន ហើយឱ្យគាត់បង្វិលត្បាល់កិននៅក្នុងគុក។

ប៉ុន្តែក្រោយមក សក់របស់សាំសុនក៏ចាប់ផ្តើមដុះឡើងវិញ។

ជនជាតិភីលីស្ទីនដែលបានចាប់សាំសុន បានរៀបចំពិធីជប់លៀង ដើម្បីអបអរសាទរជ័យជម្នះរបស់ពួកគេ។

ពួកជនជាតិភីលីស្ទីនទាំងអស់ បានមកជួបជុំគ្នានៅក្នុងវិហារដ៏ធំមួយ ដើម្បីមកមើលនិងប្រមាថសាំសុន។

សាំសុនបាននិយាយទៅកាន់ក្មេងប្រុសដែលដឹកដៃគាត់ថា៖ «សូមនាំខ្ញុំទៅជិតសសរដែលទ្រវិហារផង!»

បន្ទាប់មក សាំសុនបានចាប់កាន់សសរកន្លោងទាំងពីរដែលទ្រវិហារនោះ ទាំងអធិស្ឋានទៅព្រះជាម្ចាស់ថា៖

«ឱព្រះជាម្ចាស់អើយ សូមជួយទូលបង្គំលើកនេះម្តងទៀត ឱ្យទូលបង្គំអាចសងសឹកសត្រូវរបស់ទូលបង្គំផង! ទូលបង្គំ នឹងស្លាប់ទៅជាមួយពួកទាំងនេះ»។

ក្រោយអធិស្ឋានចប់ សាំសុនបានបញ្ចេញអស់ទាំងកម្លាំងរុញច្រានសសរនោះ។

ភ្លាមនោះ អគារវិហារនោះក៏បានដួលរលំ ធ្វើឱ្យជនជាតិភីលីស្ទីនដែលនៅទីនោះទាំងអស់បានស្លាប់។

ចំនួនអ្នកស្លាប់នៅពេលនោះ មានចំនួនច្រើនជាងអ្នកដែលលោកបានសម្លាប់កាលពីលោកនៅមានជីវិតទៅទៀត។

ដូច្នេះលោកសាំសុនក៏បានស្លាប់ទៅជាមួយពួកជនជាតិភីលីស្ទីនទៅ។



**សកម្មភាពទី១** សូមកាត់បំណែករូប(ផ្ទូហ្សល) តាមបន្ទាត់ ហើយផ្គុំរូបឡើងវិញ។



**សកម្មភាពទី២** សូមឆ្លើយសំណួរខាងក្រោម។

a. ហេតុអ្វីបានជាព្រះជាម្ចាស់ទ្រង់ធ្វើឱ្យសាសន៍អ៊ីស្រាអែលរងការលំបាក តាមរយៈពួកភីលីស្ទីន?

---

b. តើនរណាបានប្រទានកម្លាំងទៅឱ្យ សាំសុន?

---

c. ហេតុអ្វីបានជាសាំសុនបាត់បង់កម្លាំងរបស់គាត់?

---



- សូមអានខគម្ពីរ និងទន្ទេញ។ (ចៅហ្វាយ ១៦៖២០)

លោកនឹងរំដោះខ្លួន ដូចសព្វមួយដង ព្រោះលោកពុំបានដឹងថាព្រះអម្ចាស់ថយចេញពីលោកនោះទេ។